ព្រះរាជាណាចក្រកម្ពុជា

តុលាការកំពូល ជាតិ សាសនា ព្រះមហាក្សត្រ

សំណុំរឿងព្រហ្មទណ្ឌសើរើ **នាមនាមប្រជារាស្ត្រខ្មែរ**

លេខ : ០៣ ស.រ **តុលាការកំពូល**

ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០០៤

សាលដីកា បានបើកសវនាការជំនុំជំរះជាសាធារណៈនៅថ្ងៃទី ០៤ ខែ ឧសភា

លេខ : ៣០ ឆ្នាំ២០០៥ ដោយមានសមាសភាពក្រុមប្រឹក្សាជំនុំជំរះ ដូចតទៅ :

ចុះថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០០៥

| | | |
|---|---|---|
| ១- ឯកឧត្តម | **ឃឹម ប៊ុណ្ណ** | ប្រធាន |
| ២- លោក | ឈឹម ស៊ីផល | ចៅក្រម |
| ៣- លោក | ប្រាក់ គឹមសាន | ចៅក្រម |
| ៤- លោក | គង់ ភិរុន | ចៅក្រម |
| ៥- លោក | ស៊ិន ឌីម | ចៅក្រម |
| ៦- លោក | យស់ សួខឿន | ចៅក្រម |
| ៧- លោក | សោម ស៊ិរិវឌ្ឍ | ចៅក្រម-របាយការណ៍ |
| ៨- លោក | ប៉ែន សារឿន | ចៅក្រម |
| ៩- លោក | ម៉ុង មុន្នីចរិយា | ចៅក្រម |

ក្រឡាបញ្ជី

លោក សុខ ប៊ុនសង

តំណាងមហាអយ្យការ

លោក ឈួន ចាន់ថា ព្រះរាជអាជ្ញា

ដើម្បីជំនុំជំរះលើបណ្តឹងសើរើ ពីសាលដីកាព្រហ្មទណ្ឌស្ថាពរ លេខ០៣ ចុះថ្ងៃទី០៤ ខែកុម្ភៈ ឆ្នាំ២០០៤ របស់តុលាការកំពូល និង សំណុំរឿង ព្រហ្មទណ្ឌសើរើលេខ០៣ស.រ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០០៤ របស់តុលាការកំពូល ។

***ទីចទ*** : បង្ករបួសស្នាមដោយចេតនា ប្រព្រឹត្តនៅភូមិជើងខាល ឃុំម៉ង់រៀវ ស្រុកត្បូងឃ្មុំ ខេត្តកំពង់ចាម កាលពីថ្ងៃទី១៣ ខែមេសា ឆ្នាំ២០០០ ។

១-ទណ្ឌិតឈ្មោះកង ហេន (ជាម្ចាស់បណ្តឹងសើរើ) ភេទប្រុស អាយុ២០ឆ្នាំ ជាតិខ្មែរ មុខរបរកសិករ ទីលំនៅកំណើត និង សព្វថ្ងៃ ភូមិជើងខាល ឃុំម៉ង់រៀវ ស្រុកត្បូងឃ្មុំ ខេត្តកំពង់ចាម ឪពុកឈ្មោះកង ណើម "រ" ម្តាយឈ្មោះជុំ យោ "រ" នៅលីវ ។

២-ទណ្ឌិតឈ្មោះកង ហ៊ន់ (ជាម្ចាស់បណ្ដឹងសើរើ) ភេទប្រុស អាយុ២២ឆ្នាំ ជាតិខ្មែរ កើត និង ទីលំនៅសព្វថ្ងៃ ភូមិជើងខាល ឃុំម៉ង់រៀវ ស្រុកត្បូងឃ្មុំ ខេត្តកំពង់ចាម ឪពុកឈ្មោះ កង ណើម "រ" ម្ដាយឈ្មោះជុំ យោ "រ" នៅលីវ ។

៣-ទណ្ឌិតឈ្មោះជា ពិសិដ្ឋ (ជាម្ចាស់បណ្ដឹងសើរើ) ភេទប្រុស អាយុ២០ឆ្នាំ ជាតិខ្មែរ កើត និង ទីលំនៅសព្វថ្ងៃ ភូមិជើងខាល ឃុំម៉ង់រៀវ ស្រុកត្បូងឃ្មុំ ខេត្តកំពង់ចាម ឪពុកឈ្មោះជា ស៊ាង "រ" ម្ដាយឈ្មោះកង ញ៉ូ "រ" នៅលីវ ។

៤-ទណ្ឌិតឈ្មោះមាន គីមស្រាន (ជាម្ចាស់បណ្ដឹងសើរើ) ភេទប្រុស អាយុ១៨ឆ្នាំ ជាតិខ្មែរ ទីលំនៅកើត និង សព្វថ្ងៃ ភូមិជើងខាល ឃុំម៉ង់រៀវ ស្រុកត្បូងឃ្មុំ ខេត្តកំពង់ចាម ឪពុកឈ្មោះ "រ" ម្ដាយឈ្មោះយូ សេង អ៊ន់ "រ" នៅលីវ ។

-មេធាវី : គ្មាន

+ ដើមបណ្ដឹងរដ្ឋប្បវេណី

១-ឈ្មោះ តែ ទិត ភេទប្រុស អាយុ៣៣ឆ្នាំ ទីលំនៅសព្វថ្ងៃ ភូមិ មង់ទី៦ ឃុំមង់រៀវ ស្រុកត្បូងឃ្មុំ ខេត្តកំពង់ចាម ។

២-ឈ្មោះ តែ ចុង ភេទប្រុស អាយុ៤៦ឆ្នាំ ជាតិខ្មែរ ទីលំនៅសព្វថ្ងៃ ភូមិជើងខាល ឃុំមង់រៀវ ស្រុកត្បូងឃ្មុំ ខេត្តកំពង់ចាម ។

៣-ឈ្មោះ កង ញ៉ូ ភេទស្រី អាយុ៤៨ឆ្នាំ និងឈ្មោះកង ហុន ភេទស្រី អាយុ៣៩ឆ្នាំ ទីលំនៅសព្វថ្ងៃភូមិជើងខាល ឃុំមង់រៀវ ស្រុកត្បូងឃ្មុំ ខេត្តកំពង់ចាម ។

តាមពាក្យហេតុបណ្ដឹងចុះថ្ងៃទី១៤ ខែមេសា ឆ្នាំ២០០០ របស់ឈ្មោះតែ ចុង ប្ដឹងពីឈ្មោះ ហ៊ាត ម៉ានិត ,ជា ពិសិដ្ឋ ,កង ហេន ,កង ហ៊ន់ និងឈ្មោះមាន គីមស្រ៊ាន ដោយហេតុថា នៅយប់ថ្ងៃទី១២ ខែមេសា ឆ្នាំ២០០០ កូនខ្លួនឈ្មោះតែ វុទ្ធី និង ភ៊ាត កុម្ភៈ ទើបមកពីភ្នំពេញ លេងបុណ្យចូលឆ្នាំនៅវត្តមង់ រួចចូលលេងផ្ទះជីដូន ហើយពេញចេញមកវិញដល់ក្លោងទ្វារសាលាព្រៃកោះបានហួចលេង រួចពួកប្រាំនាក់ខាងលើបានស្រែកជេរថា : អាខ្មែណាហួចថ្លង់ណាស់ រួចពួកវាព្រួតគ្នាវ៉ៃតែម្ដង បណ្ដាលអោយអ្នកទាំងពីរ (តែ វុទ្ធី ,ភ៊ាត កុម្ភៈ)ទទួលរងយ៉ាងដំណំ រួចក៏រត់ទៅផ្ទះឪពុកមា ឈ្មោះ តែ ទិត្យ ដើម្បីអោយជូនមកផ្ទះ។ ពេល តែ ទិត្យ ជូនមកដល់ស្ពានទី១ បានជួបនឹងពួកនេះ ក៏ឈប់ម៉ូតូសួរថា មានការអី ស្រាប់តែពួកវាមកវាយម្ដងទៀត ដោយចែកគ្នាវាយជាពីរក្រុម មួយក្រុមវាយ តែ ទិត្យ មួយក្រុមទៀតវាយ តែ វុទ្ធី រហូតដល់អ្នកទាំងពីរលើបលែងរួច ហើយអង្វរសុំអោយពួកវាឈប់វាយ ។ ខ្លួនទាមទារអោយជនស្មើសបង់ជម្ងឺចិត្ត និង ថ្លៃថ្នាំព្យាបាលចំនួន២.០០០.០០០រៀល និង សុំអោយផ្ដន្ទាទោសតាមច្បាប់។ រីឯឈ្មោះតែ ទិត្យ បានទាមទារអោយជនល្មើសសងខ្សែកមួយតម្លឹង និង ថ្លៃថ្នាំព្យាបាល១.០០០:០០០រៀល ។

តាមពាក្យបណ្ដឹងចុះថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០០០ របស់ឈ្មោះកង ញ៉ូ និងកង ហុន ប្ដឹងពីឈ្មោះតែ វុទ្ធី ,តែ ទិត និ ង ភ៊ាត កុម្ភៈ ពីបទបង្ករបួសស្នាមដោយចេតនា កាលពីថ្ងៃទី១៣ ខែមេសា

ឆ្នាំ២០០០ ប្រហែលម៉ោង១០យប់ ដោយប្អូនខ្លួនឈ្មោះកង ហេន និងមានគ្នាបីនាក់ទៀត ពេលត្រឡប់ពីវត្តមង់រៀវ មកដល់សាលារៀនព្រៃកោះ ស្រាប់តែមានកងជិះមានគ្នាពីរនាក់គឺឈ្មោះតៃ វុទ្ធី និងវ៉ាត កុម្ភៈ មកពីក្រោយហួចឆ្វេក១ស៊ុំផ្លូវ អ្នកទាំងបួននាក់ថា អ្នកហួចហ្នឹងមើលពួកអ្នកដើរដូចជាឆ្កែ រួចអ្នកជិះកង់ឈប់ ហើយច្របាច់ពិលដាក់មុខអ្នកដើរ ក៏បានជជែកប្រតាយប្រតប់គ្នារួចបែកគ្នាទៅ លុះដើរមកដល់ចំណុចស្ពានទី១ ភូមិជើងខាល ឃើញម៉ូតូវីវ៉ាជិះឌុបគ្នាបីនាក់ មកដល់ស្ពានស្រាប់ ផ្តួលម៉ូតូ គឺឈ្មោះតៃ ទិត ទិត វុទ្ធី និង វ៉ាត កុម្ភៈ ដែលពីរនាក់មានកាន់ព្រនង រួចស្ទុះមកដេញវ៉ៃប្អូន ខ្លួន ហើយឈ្មោះពីរនាក់ទៀត ឈ្មោះតៃ វុទ្ធី និង វ៉ាត កុម្ភៈ ដៃកាន់ឈើជ្រូងនោះមកវាយឈ្មោះកង ហេន បណ្តាលឱ្យមានរបួសត្រង់ក្បាលជាទំងន់ និង ចាប់ច្របាច់កឈ្មោះជា ពិសិដ្ឋ ទៀត ។

- បានឃើញសេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ អមតុលាការខេត្តកំពុងចាម ថា : ចោទប្រកាន់លើឈ្មោះ :

១- កង ហេន អាយុ២០ឆ្នាំ ភេទប្រុស ជាតិខ្មែរ (ក្រៅឃុំ)
២- កង ហ៊ន់ អាយុ២២ឆ្នាំ ភេទប្រុស ជាតិខ្មែរ (ក្រៅឃុំ)
៣- ជា ពិសិដ្ឋ អាយុ២០ឆ្នាំ ភេទប្រុស ជាតិខ្មែរ (ក្រៅឃុំ)
៤- មាន គីមស្រ៊ាន អាយុ១៨ឆ្នាំ ភេទប្រុស ជាតិខ្មែរ (ក្រៅឃុំ )
៥- ហ៊ាត និត អាយុ១៨ឆ្នាំ ភេទប្រុស ជាតិខ្មែរ (ឃាត់ខ្លួនថ្ងៃទី០៨-៨-២០០០)
៦- តៃ វុទ្ធី អាយុ២២ឆ្នាំ ភេទប្រុស ជាតិខ្មែរ (ក្រៅឃុំ)
៧- វ៉ាត កុម្ភៈ អាយុ១៨ឆ្នាំ ភេទប្រុស ជាតិខ្មែរ (ក្រៅឃុំ) ។

ពីបទ : បង្ករបួសស្នាមដោយចេតនា ប្រព្រឹត្តនៅភូមិជើងខាល ឃុំមង់រៀវ ស្រុកត្បូងឃ្មុំ ខេត្តកំពង់ចាម កាលពីថ្ងៃទី១៣ ខែមេសា ឆ្នាំ២០០០ បទល្មើសដែលមានចែងអោយផ្តន្ទា ទោសតាមមាត្រា៤១ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

- បានឃើញសាលក្រមព្រហ្មទណ្ឌលេខ២០៥"ក"ចុះថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០០០របស់តុលាការខេត្តកំពង់ចាម ដែលមានខ្លឹមសារដូចតទៅ :

១-ផ្តន្ទាទោសឈ្មោះកង ហេន ភេទប្រុស អាយុ២០ឆ្នាំ និង ឈ្មោះហ៊ាត និត ភេទប្រុស អាយុ១៨ឆ្នាំ ដាក់ពន្ធនាគារកំណត់៩ខែ គិតពីថ្ងៃចាប់ខ្លួន ពីបទបង្ករបួសស្នាមដោយចេតនាប្រព្រឹត្តនៅភូមិជើងខាល ឃុំមង់រៀវ ស្រុកត្បូងឃ្មុំ ខេត្តកំពង់ចាម កាលពីថ្ងៃទី១៣ ខែមេសា ឆ្នាំ ២០០០ តាមមាត្រា៤១ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

២-ផ្តន្ទាទោសឈ្មោះកង ហ៊ន់ ភេទប្រុស អាយុ២២ឆ្នាំ ,ឈ្មោះជា ពិសិដ្ឋ ភេទប្រុស អាយុ១៨ឆ្នាំ ,មាន គីមស្រ៊ាន ភេទប្រុស អាយុ១៨ឆ្នាំ ឈ្មោះតៃ វុទ្ធី ភេទប្រុស អាយុ២២ឆ្នាំ និង ឈ្មោះវ៉ាត កុម្ភៈ ភេទប្រុស អាយុ១៨ឆ្នាំ ដាក់ពន្ធនាគារកំណត់៦ខែ តែទោសនេះត្រូវព្យួររយៈពេល សាកល្បង ០៥ឆ្នាំ គិតពីថ្ងៃប្រកាសសាលក្រមនេះតទៅ ពីបទបង្ករបួសស្នាមដោយចេតនា ប្រព្រឹត្តនៅ ភូមិមង់រៀវ

ស្រុកត្បូងឃ្មុំ ខេត្តកំពង់ចាម កាលពីថ្ងៃទី១៣ ខែមេសា ឆ្នាំ២០០០ តាមមាត្រា៤១ និង ៧០ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

៣-អោយឈ្មោះកង ហេន ,កង ហ៊ាន់-,ជា ពិសិដ្ឋ ,ហ៊ាត និត និងឈ្មោះមាន គឹមស្រ៊ាន រួមគ្នាសងសំណងថ្លៃថ្នាំព្យាបាល និង ជម្ងឺចិត្តអោយទៅដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះតែ ទិត្យ ចំនួន ៧.០០០.០០០រៀល និង អោយទៅដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះតែ ថុង ៧.០០០.០០០រៀល ។ ការទាមទារលើសពីនេះបដិសេធចោល ។

- អោយឈ្មោះតែ វុទ្ធី និង វ៉ាត កុម្ភៈ រួមគ្នាសងថ្លៃថ្នាំព្យាបាល និង ជម្ងឺចិត្តឱ្យទៅដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះកង ហុន ចំនួន៣.០០០.០០០រៀល និង ឱ្យទៅដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះកង ញ៉ ចំនួន១.០០០.០០០រៀល ការទាមទារលើសពីនេះ បដិសេធចោល ។

- នៅពេលសាលក្រមនេះចូលជាស្ថាពរ បើឈ្មោះខាងលើពុំព្រមសងសំណងនេះទេ អនុញ្ញាតអោយលក់ឡាយឡុងទ្រព្យសម្បត្តិអ្នកទាំងនោះ សងអោយដើមបណ្ដឹងគ្រប់ចំនួន ។ បើមានឧបាយកលទុច្ចរិត អនុញ្ញាតឱ្យដាក់គុកបង្ខំរូបកាយតាមមាត្រា៧ នៃច្បាប់ស្ដីពីការដាក់គុកបង្ខំលើរូបកាយក្នុងរឿងព្រហ្មទណ្ឌ។

៤-វត្ថុតាង កាំភ្លើងខ្លីជ័រពណ៌ខ្មៅ១ ,ឈើជ្រុងទំហំ 0,9m×0.04m ១ ដែកគាស់ជើងជ្រូក១ ,អាវយឺតប្រឡាក់ឈាម១ ,ស្បែកជើងស៊កពណ៌កាហ្វេ១ចំហៀង ត្រូវរឹបអូស និង បំផ្លាញចោល។

៥-សាលក្រមនេះប្រកាសជាសាធារណៈចំពោះមុខជនល្មើសនិងដើមបណ្ដឹងរដ្ឋប្បវេណី។ បើកសិទ្ធិអោយប្ដឹងឧទ្ធរណ៍តាមកំណត់ច្បាប់ ។

- បានឃើញបណ្ដឹងឧទ្ធរណ៍លេខ៦៥ ចុះថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០០០ របស់ឈ្មោះហ៊ាត ម៉ានិត ប្ដឹងមិនសុខចិត្តត្រង់ចំណុចទី៣ នៃសាលក្រម ។

- បានឃើញបណ្ដឹងឧទ្ធរណ៍លេខ៦៦ ចុះថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០០០ របស់ឈ្មោះជា ពិសិដ្ឋ ប្ដឹងមិនសុខចិត្តនឹងសេចក្ដីសំរេចទាំងមូល នៃសាលក្រម ។

- បានឃើញបណ្ដឹងឧទ្ធរណ៍លេខ៦៧ ,៦៨ ចុះថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០០០របស់ឈ្មោះកង ហ៊ាន់ កង ហេន ប្ដឹងមិនសុខចិត្តនឹងសេចក្ដីសំរេចទាំងមូល នៃសាលក្រម ។

- បានឃើញបណ្ដឹងឧទ្ធរណ៍លេខ១៣ ,១៤ ចុះថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០០១ របស់ឈ្មោះតែ វុទ្ធី , វ៉ាត កុម្ភៈ ប្ដឹងមិនសុខចិត្តនឹងសេចក្ដីសំរេចទាំងមូល នៃសាលក្រម ។

- បានឃើញសេចក្ដីសន្និដ្ឋានរបស់តំណាងមហាអយ្យការ អមសាលាឧទ្ធរណ៍ថា :

១-ទទួលបណ្ដឹងឧទ្ធរណ៍ចុះថ្ងៃទី១៣ ,១៤ ,៦៥ ,៦៨ ,ចុះថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ ២០០១ ,២៦ ខែធ្នូ ឆ្នាំ២០០០ ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ តែបដិសេធចោល ដោយទាស់នឹងគតិ ច្បាប់ ។

២-តម្កល់សាលក្រមលេខ២០៥ ចុះថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០០០ ទុកជាបានការតទៅ។

- បានឃើញសាលដីកាព្រហ្មទណ្ឌលេខ០៧"ឈ" ចុះថ្ងៃទី២៤ ខែមេសា ឆ្នាំ២០០២ របស់សាលាឧទ្ធរណ៍ ដែលមានខ្លឹមសារនៃសេចក្ដីសំរេចដូចតទៅ :

១-ទទួលពាក្យបណ្ដឹងឧទ្ធរណ៍ ចុះថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០០០ របស់ឈ្មោះកង ហ៊ាន់ កង ហេន ,ជាពិសិដ្ឋ និង ហ៊ាត ម៉ានិត ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ តែបដិសេធចោលដោយទាស់នឹងគតិច្បាប់ ។

២-ទទួលពាក្យបណ្ដឹងឧទ្ធរណ៍ចុះថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០០១ របស់ឈ្មោះតៃ វុទ្ធី និង វ៉ាត កុម្ភៈ ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ តែបដិសេធចោលដោយទាស់នឹងគតិច្បាប់ ។

៣-តំកល់សាលក្រមព្រហ្មទណ្ឌលេខ២០៥ "ក" ចុះថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០០០ របស់តុលាការខេត្តកំពង់ចាម ទុកជាបានការដដែល ។

៤-សាលដីកានេះបានជំនុំជំរះ ជាសាធារណៈ នៅថ្ងៃទី១៩ ខែមេសា ឆ្នាំ២០០២ ចំពោះមុខជនជាប់ចោទ ឈ្មោះកង ហេន ,ជា ពិសិដ្ឋ ,មាន គីម់ស្រ៊ាន ,តៃ វុទ្ធី មេធាវីការពារជនជាប់ចោទ និងដើម បណ្ដឹងរដ្ឋប្បវេណីឈ្មោះតៃ ទិត្យ និងតៃ ថុង និងប្រកាសជាសាធារណៈនៅថ្ងៃទី២៤ ខែមេសា ឆ្នាំ២០០២ ចំពោះមុខជនជាប់ចោទឈ្មោះតៃ វុទ្ធី កំបាំងមុខជនជាប់ចោទឈ្មោះ កង ហេន ,កង ហ៊ាន់ ជា ពិសិដ្ឋ ,ហ៊ាត ម៉ានិត ,វ៉ាត កុម្ភៈ និងដើមបណ្ដឹងរដ្ឋប្បវេណី ឈ្មោះតៃ ទិត្យ និង តៃ ថុង បើកផ្លូវប្ដឹងតវ៉ាតាមកំណត់ច្បាប់ ។

- បានឃើញបណ្ដឹងសាទុក្ខលេខ២៤ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០២ របស់ឈ្មោះជា ពិសិដ្ឋ កង ហេន ,ហ៊ាត ម៉ានិត និង កង ហ៊ាន់ ប្ដឹងមិនសុខចិត្តនឹងសាលដីកាព្រហ្មទណ្ឌលេខ០៧"ឈ" ចុះថ្ងៃទី២៤ ខែមេសា ឆ្នាំ២០០២ របស់សាលាឧទ្ធរណ៍ ត្រង់ចំណុចនៃសេចក្ដីសំរេចទាំងមូល ។

-បានឃើញសាលដីកាព្រហ្មទណ្ឌលេខ០៣ ចុះថ្ងៃទី០៤ ខែកុម្ភៈ ឆ្នាំ២០០៤ របស់តុលាការកំពូល ដែលបានសំរេច :

១-ទទួលបណ្ដឹងសាទុក្ខលេខ២៤ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០២ របស់ឈ្មោះ កង ហេន ,កង ហ៊ាន់ ,ជា ពិសិដ្ឋ និង ហ៊ាត ម៉ានិត ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ ប៉ុន្តែបដិសេធចោលដោយខុស នឹងគតិច្បាប់ ។

២-តម្កល់សាលដីកាព្រហ្មទណ្ឌលេខ០៧"ឈ" ចុះថ្ងៃទី២៤ ខែមេសា ឆ្នាំ២០០២ របស់សាលាឧទ្ធរណ៍ ទុកជាបានការពេញទាំងមូល ។

៣-សាលដីកានេះប្រកាសជាសាធារណៈ នៅថ្ងៃទី០៤ ខែកុម្ភៈ ឆ្នាំ២០០៤ ។

-បានឃើញបណ្ដឹងសើរើ ចុះថ្ងៃទី១៥ ខែមីនា ឆ្នាំ២០០៤ របស់ទណ្ឌិតឈ្មោះកង ហេន ,កង ហ៊ាន់ ជា ពិសិដ្ឋ ,មាន គីម ស្រ៊ាន និង ហ៊ាត ម៉ានិត ប្ដឹងមិនសុខចិត្តពីសាលដីកាព្រហ្មទណ្ឌស្ថាពរលេខ០៣ ចុះថ្ងៃទី០៤ ខែកុម្ភៈ ឆ្នាំ២០០៤ របស់តុលាការកំពូល ។

-បានឃើញលិខិតបំភ្លឺ ចុះថ្ងៃទី១៥ ខែមីនា ឆ្នាំ២០០៤ របស់ឈ្មោះកើត សុខកល់ ។

-បានឃើញលិខិតបំភ្លឺ ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ២០០៤ របស់ឈ្មោះពូក រតនៈ ។

-បានឃើញលិខិតបំភ្លឺ ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ២០០៤ របស់ឈ្មោះកើត សុភ៊ា ។

-បានឃើញលិខិតបំភ្លឺ ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ២០០៤ របស់ឈ្មោះភាំ ឡឿន ,កុយ សៅ ,កួន ណាក់ និង ហុង បូរ៉ា ។

- បានស្តាប់ចៅក្រមរបាយការណ៍ អានរបាយការណ៍

- បានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ អមតុលាការកំពូល ថា : ទណ្ឌិតឈ្មោះ កង ហោន ,កង ហ៊ាន់ ,ជា ពិសិដ្ឋ ,ហ៊ាត ម៉ានិត និង មាន គីមស្រាន ដែលបានជូននូវសេចក្តីបំភ្លឺរបស់ឈ្មោះ កើត សុកល់ , កើត សុភ៊ា ,ពូក រតនា ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ២០០៤ និងឈ្មោះភាំ ធឿន ,កុយ សៅ , កួន ហាក់ និង ហុង បូរ៉ា ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ២០០៤ ជាភស្តុតាងថ្មីក្នុងបណ្តឹងសើរើរបស់ខ្លួននោះ គឺពុំ មានអ្វីប្លែកទេ ។ សូមក្រុមប្រឹក្សាជំនុំជំរះពិនិត្យ និង សំរេច ។

-បានស្តាប់ក្រឡាបញ្ជីអានសាវតាជាតិ និង ពាក្យបណ្តឹងសើរើរបស់ទណ្ឌិត នៅពេលជំនុំជំរះ ។

-បានស្តាប់ក្រឡាបញ្ជីអានពាក្យបំភ្លឺរបស់សាក្សី នៅពេលជំនុំជំរះ ។

-បានស្តាប់សេចក្តីសន្និដ្ឋានបន្ថែមរបស់តំណាងមហាអយ្យការ អមតុលាការកំពូល នៅពេលជំនុំ ជំរះ ថា : គ្មានយោបល់បន្ថែម ។

-ក្រោយពីបានស្តាប់របាយការណ៍ របស់ចៅក្រមរបាយការណ៍

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋាន របស់តំណាងមហាអយ្យការ

-ក្រោយពីបានស្តាប់ពាក្យបណ្តឹងសើរើរបស់ទណ្ឌិត

-ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ ។

## តុលាការកំពូល

-យល់ឃើញថា បណ្តឹងសើរើចុះថ្ងៃទី១៥ ខែមីនា ឆ្នាំ២០០៤ របស់ទណ្ឌិតកង ហេង , កង ហ៊ាន់ ជា ពិសិដ្ឋ ,មាន គីមស្រាន ,ហ៊ាត ម៉ានិត ធ្វើឡើងត្រឹមត្រូវតាមទំរង់ច្បាប់ តុលាការកំពូលអាចលើករឿង នេះមកជំនុំជំរះបានដោយយោងតាមមាត្រា២២៧ នៃច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌ ។

-យល់ឃើញថា សេចក្តីបំភ្លឺរបស់ឈ្មោះកើត សុខកាល ,ពូត រតនៈ ,កើត សុភ៊ា ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ២០០៤ និង សេចក្តីបំភ្លឺរបស់ឈ្មោះភាំ ធឿន ,កុយ សៅ ,គួន ណាក់ ,ហុង បូរ៉ា ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ២០០៤ ដែលទណ្ឌិត កង ហោន ,កង ហ៊ាន់ ,ជា ពិសិដ្ឋ ,មាន គីមស្រាន ,ហ៊ាត ម៉ានិត បានជូន ជាភស្តុតាងថ្មី ក្នុងបណ្តឹងសើរើរបស់ខ្លួននោះ ពុំមានលក្ខណៈដោះបន្ទុកដូចការកំណត់ក្នុងមាត្រា២៣០ នៃ ច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌឡើយ ដែលគប្បីតុលាការកំពូលលើកបណ្តឹងសើរើនេះចោលជាអសារបង់ ។

## ហេតុដូច្នេះ

## វិនិច្ឆ័យសេចក្តី

១-លើកបណ្តឹងសើរើ ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០០៤ របស់ទណ្ឌិត កង ហេន ,កង ហ៊ាន់ ជា ពិសិដ្ឋ ,មាន គីមស្រ៊ាន ,ហ៊ាត ម៉ានិត ចោលជាអសារបង់ ។

២-សាលដីកានេះ ប្រកាសនូសវនាការជាសាធារណៈនៅថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០០៥ ។